នៅពេលដែលកម្មករនិយោជិតបានប្រព្រឹត្តនៅកំហុសធ្ងន់ សហគ្រាសមិនមានកាតព្វកិច្ចក្នុងការជូនដំណឹងមុនទេ។

រាល់ពេលបញ្ចប់កិច្ចសន្យាការងារមានកំណត់ចិរវេលា សហគ្រាសនឹងជូនដំណឹងមុនជាលាយលក្ខណ៍អក្សរ យោងតាមរយៈពេលនៃកិច្ចសន្យាការងារ គឺអនុវត្តដូចខាងក្រោម ៖

| ចិរវេលានៃការងារ | ចិរវេលាដែលត្រូវឱ្យដំណឹងមុន |
|---|---|
| ក្រោម៦ខែ ឬតិចជាង៦ខែ | មិនចាំបាច់ជូនដំណឹងមុន |
| លើសពី ៦ខែ ដល់ ១ឆ្នាំ | ១០ថ្ងៃ |
| លើសពី ១ឆ្នាំឡើងទៅ | ១៥ថ្ងៃ |

## ជំពូកទី៣
## សុវត្ថិភាព និងសុខភាពការងារ

### ប្រការ១៦._ សុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការ

កម្មករនិយោជិតត្រូវគោរពតាមវិធានការសុវត្ថិភាពនៅកន្លែងធ្វើការ ដូចខាងក្រោម៖

- ត្រូវរក្សាអនាម័យឱ្យបានស្អាតក្នុងពេលបំពេញការងារនិងអនាម័យទីកន្លែងធ្វើការឱ្យបានស្អាតជាប្រចាំ
- មិនត្រូវអនុវត្តការងារខុសពីភារកិច្ចឡើយដើម្បីជៀសវាងគ្រោះថ្នាក់ការងារនិងមហន្តរាយផ្សេងៗ។
- ត្រូវអនុវត្តការងារតាមរបៀបរបបបច្ចេកទេសដែលសហគ្រាសបានណែនាំ និងប្រើប្រាស់សម្ភារការពារពលកម្មដែលសហគ្រាសបានចែកជូនឱ្យបានជាប្រចាំ។
- នៅពេលពិនិត្យឃើញគ្រឿងចក្រ សម្ភារ និងហត្ថបករណ៍របស់សហគ្រាស មានលក្ខណៈខុសប្រក្រតីដែលអាចបង្កឱ្យមានគ្រោះថ្នាក់ កម្មករនិយោជិតត្រូវរាយការណ៍ជូនសហគ្រាសជាបន្ទាន់ដើម្បីមានវិធានការជួសជុលកែសម្រួល។

កម្មករនិយោជិតត្រូវគោរព និងប្រតិបត្តិនូវវិធានខាងសុវត្ថិភាព និងសុខភាពការងារ ដែលសហគ្រាសធ្វើការបង្ហាត់បង្រៀនជូន។

ថ្ងៃ...........................ខែ.............ឆ្នាំ............ស័ក ព.ស......

.......... ថ្ងៃទី.......... ខែ........... ឆ្នាំ..........

**ហត្ថលេខា**

**ម្ចាស់ ឬនាយក**

លេខ: IR20200006
បានឃើញ និងបញ្ជាក់ថា ត្រឹមត្រូវ
ត្បូងឃ្មុំ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០
ចេញដោយ រដ្ឋបាល
ខេត្តត្បូងឃ្មុំ

ទិន្នន័យដែលត្រឹមត្រូវ គឺមាននៅលើគេហទំព័រ
https://www.lacms.mlvt.gov.kh